Legal Services
Commission South Australia

# LAW FOR YOU

## ការណែនាំខ្លីៗអំពីច្បាប់ សម្រាប់ជនអន្តោប្រវេសន៍ថ្មីដែល រស់នៅក្នុងរដ្ឋអូស្ត្រាលី

**KHMER**



# មាតិកា


| | |
|---|---|
| សេចក្តីផ្តើម | 1 |
| ច្បាប់នៅប្រទេសអូស្ត្រាលី | 2 |
| ការបើកបរ | 3 |
| ការទិញរថយន្តដែលគេប្រើរួចហើយ | 4 |
| គ្រោះថ្នាក់ចរាចរណ៍ | 5 |
| ការទិញទំនិញ និងសេវាកម្ម | 6 |
| ប៉ូលីស | 7 |
| អំពើហិង្សាក្នុងគ្រួសារ | 8 |
| ការជួលទីលំនៅ | 9 |
| អាពាហ៍ពិពាហ៍ | 10 |
| ការបែកគ្នា និងការលែងលះគ្នា | 11 |
| កុមារ និងការបែកគ្នា | 12 |
| ការថែទាំកុមារ | 13 |
| ការសម្រេចចិត្តរបស់រដ្ឋាភិបាល | 14 |
| ការងារ | 15 |
| ការផាកពិន័យ | 16 |

# ច្បាប់សម្រាប់អ្នក

## ការណែនាំខ្លីៗអំពីច្បាប់សម្រាប់ជនអន្តោប្រវេសន៍ថ្មី ដែលរស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង

នេះគឺជាការណែនាំជាមូលដ្ឋានអំពីច្បាប់សម្រាប់ជនអន្តោប្រវេសន៍ថ្មីដែលរស់នៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង។ វាមានគោលបំណងដើម្បីជួយអ្នកដែលមិនចេះនិយាយភាសាអង់គ្លេស រៀន ដឹងពីច្បាប់សំខាន់ៗ និងស្វែងយល់អំពីសេវាកម្មនានាដែលមានផ្តល់ជូន ដើម្បីជួយមនុស្សដែលមានបញ្ហាផ្លូវច្បាប់។ ប្រសិនបើនរណាម្នាក់មានបញ្ហាផ្លូវច្បាប់ វាសំខាន់ដែលត្រូវទទួលបានដំបូន្មានផ្លូវច្បាប់ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

មគ្គុទ្ទេសក៍នេះត្រូវបានបង្កើតឡើងដោយគណៈកម្មការសេវាកម្មច្បាប់ (Legal Services Commission) ដើម្បីគាំទ្រដល់ការអប់រំផ្នែកច្បាប់សម្រាប់ជនអន្តោប្រវេសន៍ថ្មី។ វាក៏អាចត្រូវបានប្រើប្រាស់ផងដែរ ដោយអ្នកដែលត្រូវការយល់ដឹងអំពីគោលគំនិតច្បាប់ជាមូលដ្ឋាន និងកន្លែងដែលត្រូវទទួលបានជំនួយ។

តើអ្នកមានសំណួរអំពីសិទ្ធិផ្លូវច្បាប់របស់អ្នក ឬត្រូវការជំនួយជាមួយបញ្ហាផ្លូវច្បាប់ទេ? សូមអញ្ជើញទៅគណៈកម្មការសេវាកម្មច្បាប់ (Legal Services Commission) ដើម្បីទទួលបានដំបូន្មាន និងព័ត៌មានដោយឥតគិតថ្លៃ។ មេធាវីរបស់យើងអាចជួយអ្នកតាមទូរសព្ទ ឬតាមការណាត់ជួប។ នេះជាការសម្ងាត់ ហើយមេធាវីអាចរៀបចំ និងបង់ប្រាក់ជូនអ្នកសម្រាប់អ្នកបកប្រែផ្ទាល់មាត់។ ទូរសព្ទទៅបណ្តាញទូរស័ព្ទជំនួយផ្នែកច្បាប់ តាមលេខ 1300 366 424។ សេវាកម្មនេះមានផ្តល់ជូនចាប់ពីម៉ោង 9 ព្រឹកដល់ម៉ោង 4:30 ល្ងាច ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ដើម្បីជួយអ្នកទាក់ទងមក គណៈកម្មការសេវាកម្មច្បាប់ សូមទូរស័ព្ទទៅសេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS) ជាមុនសិន តាមលេខ 131 450 ហើយបន្ទាប់មកស្នើសទូរស័ព្ទមកលេខ 1300 366 424។

# ច្បាប់នៅប្រទេសអូស្ត្រាលី




- មនុស្សគ្រប់រូបត្រូវតែប្រតិបត្តិតាមច្បាប់។

- ប្រសិនបើអ្នកបំពានច្បាប់ អ្នកប្រហែលជាត្រូវបង់ប្រាក់ពិន័យ ឬទៅតុលាការ។

- ព័ត៌មានឥតគិតថ្លៃអំពីច្បាប់ គឺអាចរកបានសម្រាប់មនុស្សគ្រប់រូប។

- អ្នកអាចទទួលបានជំនួយផ្លូវច្បាប់ដោយឥតគិតថ្លៃពី គណៈកម្មការសេវាកម្មច្បាប់។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

# ការបើកបរ



- អ្នកត្រូវតែមានប័ណ្ណបើកបរត្រឹមត្រូវ ដើម្បីបើកបរនៅក្នុងរដ្ឋអូស្ត្រាលីខាងត្បូង។ ប្រសិនបើអ្នកទើបតែអញ្ជើញមកដល់ថ្មីៗក្នុងរដ្ឋអូស្ត្រាលីខាងត្បូង សូមពិនិត្យ មើលជាមួយ Service SA (ក្រសួងផ្តល់សេវាកម្ម រដ្ឋអូស្ត្រាលីខាងត្បូង) ដើម្បីឱ្យបានដឹង ថាតើប័ណ្ណបើកបររបស់អ្នកមានសុពលភាពឬអត់។

- អ្នកមិនត្រូវបើកបររថយន្តដែលមិនបានចុះបញ្ជី ឬទុករថយន្តដែលមិនបានចុះបញ្ជីចតនៅលើដងផ្លូវឡើយ។

- មនុស្សគ្រប់រូបត្រូវពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព រួមទាំងកុមារផងដែរ។ កុមារត្រូវការកៅអីរថយន្តពិសេស និងខ្សែក្រវ៉ាត់។ ប្រភេទនៃកៅអីរថយន្ត ឬខ្សែក្រវ៉ាត់ដែលអ្នកត្រូវការប្រើ អាស្រ័យលើទំហំ និងអាយុរបស់កុមារ។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមក Kidsafe SA (សុវត្ថិភាពកុមារ រដ្ឋអូស្ត្រាលីខាងត្បូង)។

- អ្នកត្រូវតែរៀន និងគោរពច្បាប់បើកបរទាំងអស់។ ការផ្តន្ទាទោសចំពោះការបំពានបទប្បញ្ញត្តិទាំងនេះ អាចរួមមានការផាកពិន័យ ការជាប់ពន្ធនាគារ និងការបាត់បង់ អាជ្ញាប័ណ្ណបើកបរ។

## សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

Service SA ( ក្រសួងផ្តល់សេវាកម្ម រដ្ឋអូស្ត្រាលីខាងត្បូង)
13 10 84

Kidsafe SA (ទីភ្នាក់ងារ សុវត្ថិភាពកុមារ រដ្ឋអូស្ត្រាលីខាងត្បូង)
8161 6318
www.kidsafesa.com.au/road-safety

# ការទិញរថយន្ត ដែលគេប្រើរួចហើយ




ការទិញពីកន្លែងលក់រថយន្តដាក់បង្ហាញនៅទីធ្លាក្រៅអគារ៖

- ស្នើសុំឱ្យជាងម៉ាស៊ីន ឬ RAA ពិនិត្យមើលរថយន្ត។
- អ្នកលក់រថយន្តត្រូវតែធ្វើឱ្យប្រាកដថារថយន្តនោះមិនមែនចោរលួច ឬស្ថិតនៅក្រោមការទិញដោយប្រាក់កម្ចី។

ការទិញជាលក្ខណៈឯកជនពីម្ចាស់៖

- ស្នើសុំឱ្យជាងម៉ាស៊ីន ឬ RAA ពិនិត្យមើលរថយន្ត។
- ពេលខ្លះធនាគារអាចរឹបអូសយករថយន្តបាន ប្រសិនបើស្ថិតនៅក្រោមការទិញ ដោយប្រាក់កម្ចី។ ករណីនេះអាចកើតឡើង សូម្បីតែបន្ទាប់ពីអ្នកទិញរថយន្ត ហើយចុះឈ្មោះវានៅក្រោមឈ្មោះរបស់អ្នកក្តី។ ដើម្បីពិនិត្យមើលថាតើរថយន្តនៅតែស្ថិតនៅក្រោមការទិញដោយប្រាក់កម្ចីឬអត់ ទូរស័ព្ទទៅនាយកដ្ឋានបញ្ជីទ្រព្យកម្មសិទ្ធិផ្ទាល់ ខ្លួន (Personal Property Securities Register) (PPSR) តាមលេខ 1300 007 777។ អ្នកនឹងត្រូវការ 'លេខអត្តសញ្ញាណរថយន្ត' 'Vehicle Identification Number' (VIN) ដែលអាចរកឃើញនៅលើក្រដាសចុះឈ្មោះ និងនៅលើម៉ាស៊ីន។ ការស្វែងរក PPSR គឺជាការចំណាយបន្តិចបន្តួច ហើយអ្នកអាចបង់បាន ដោយកាតឥណទានតែប៉ុណ្ណោះ។
- ត្រូវប្រាកដថារថយន្តមិនបានចោរលួច។ PPSR ក៏អាចពិនិត្យមើលជូនអ្នកផងដែរ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

RAA
131 111

នាយកដ្ឋានបញ្ជីទ្រព្យកម្ម សិទ្ធិផ្ទាល់ខ្លួន (Personal Property Securities Register)
1300 007 777
www.ppsr.gov.au

# គ្រោះថ្នាក់ចរាចរណ៍



- ប្រសិនបើមានគ្រោះថ្នាក់ចរាចរណ៍ អ្នកបើកបរគ្រប់រូបត្រូវតែឈប់ ហើយជួយ ប្រសិនបើមាននរណាម្នាក់រងរបួស។

- អ្នកបើកបរត្រូវតែផ្លោះប្តូរព័ត៌មានលម្អិតរបស់ពួកគេ៖ រួមមានឈ្មោះ អាសយដ្ឋាន និងក្រុមហ៊ុនធានារ៉ាប់រង។

- ធ្វើរបាយការណ៍ទៅប៉ូលីស ប្រសិនបើមាននរណាម្នាក់រងរបួស ឬថ្លៃជួសជុលលើ រថយន្តទាំងអស់មានចំនួនលើសពី $3000។

- 'ការធានារ៉ាប់រងភាគីទីបីចាំបាច់' ត្រូវបានដាក់បញ្ចូល នៅពេលអ្នកបង់ថ្លៃការចុះបញ្ជីរថយន្តរបស់អ្នក។ តម្លៃនេះបង់សំណងដល់អ្នកដែលរងរបួសក្នុងគ្រោះថ្នាក់ចរាចរណ៍។ វាមិនបង់ថ្លៃជួសជុលរថយន្តទេ។

- មានប្រភេទធានារ៉ាប់រងផ្សេងទៀតដែលអ្នកអាចទទួលបាន ដើម្បីជួសជុលរថយន្ត៖

    - 'ការធានារ៉ាប់រងលើទ្រព្យសម្បត្តិភាគីទីបី' បង់ចំពោះការខូចខាតរថយន្តរបស់អ្នកដទៃ ប្រសិនបើគ្រោះថ្នាក់ជាកំហុសរបស់អ្នក។

    - 'ការធានារ៉ាប់រងពេញលេញ' បង់ចំពោះការខូចខាតទាំងរថយន្តរបស់អ្នក និងរថយន្តរបស់អ្នកដទៃ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

ប៉ូលីស
ទូរស័ព្ទទៅលេខ 000 ក្នុងគ្រាអាសន្នបន្ទាន់ ឬលេខ 131 444 សម្រាប់វត្តមានរបស់ប៉ូលិស (មិនមែនជាករណីអាសន្នបន្ទាន់)។

# ការទិញទំនិញ និងសេវាកម្ម



- អ្នកមានសិទ្ធិ ប្រសិនបើមានអ្វីមួយដែលអ្នកទិញខូច មិនមានសុវត្ថិភាព មិនដំណើរ ការ ឬមើលទៅខុសពីរបៀបដែលវាគួរត្រូវបានរំពឹងទុក។ អ្នកអាចឱ្យគេជួសជុលវា ឬប្តូរយក ថ្មីមួយទៀត ឬទាមទារយកប្រាក់របស់អ្នកមកវិញ។ ករណីនេះអាចកើត ឡើង សូម្បីតែ បន្ទាប់ពីការធានារ៉ាប់រងបានបញ្ចប់ក្តី។
- ត្រូវរក្សាបង្កាន់ដៃជានិច្ច។
- មុនពេលអ្នកចុះហត្ថលេខាលើកិច្ចសន្យា ស្នើសុំឱ្យនរណាម្នាក់ជួយពន្យល់អ្នកឱ្យ យល់ដឹង ពីអត្ថន័យរបស់វា។ នេះមានសារៈសំខាន់ខ្លាំងណាស់សម្រាប់កិច្ចសន្យា រយៈពេលវែង ដូចជាសម្រាប់ទូរសព្ទចល័តជាដើម។
- ការបិទ 'ស្ទីគ័រ សូមកុំគោះ' ('Do Not Knock Sticker') នៅទ្វារខាងមុខរបស់អ្នក អាច បញ្ឈប់មនុស្សមកកាន់ផ្ទះរបស់អ្នក ដើម្បីលក់របស់របរឱ្យអ្នក។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

មជ្ឈមណ្ឌលច្បាប់ឥណទានសម្រាប់អ្នកប្រើប្រាស់ រដ្ឋអូស្ត្រាលីខាងត្បូង

(Consumer Credit Law Centre SA)
8342 1800
1300 886 220 (អ្នកហៅទូរសព្ទពីទីជនបទ)

# ប៉ូលីស



- ប៉ូលិសការពារសហគមន៍ និងធ្វើយ៉ាងឱ្យប្រាកដថាប្រជាពលរដ្ឋអនុវត្តតាមច្បាប់។ ប៉ូលិសក៏ត្រូវតែអនុវត្តតាមច្បាប់ផងដែរ។
- នៅពេលស៊ើបអង្កេតឧក្រិដ្ឋកម្ម ប៉ូលិសអាចសាកសួរនរណាម្នាក់។
- អ្នកមិនចាំបាច់ត្រូវឆ្លើយសំណួរណាមួយដែលប៉ូលិសសួរអ្នក ក្រៅពីប្រាប់ឈ្មោះ អាសយដ្ឋាន និងថ្ងៃខែឆ្នាំកំណើតរបស់អ្នក។
- ប្រសិនបើអ្នកកំពុងបើកបររថយន្ត អ្នកក៏ត្រូវតែបង្ហាញប័ណ្ណបើកបររបស់អ្នក ដល់ប៉ូលិសផងដែរ ប្រសិនបើពួកគេស្នើសុំវា។
- អ្នកមានសិទ្ធិទទួលបានដំបូន្មានផ្លូវច្បាប់ មុនពេលអ្នកឆ្លើយសំណួរផ្សេងទៀត ពីប៉ូលិស។
- ប្រសិនបើភាសាអង់គ្លេសមិនមែនជាភាសាដែលអ្នកពេញចិត្តទេ អ្នកមានសិទ្ធិស្នើសុំអ្នកបកប្រែផ្ទាល់មាត់ នៅពេលណាដែលអ្នកនិយាយជាមួយប៉ូលិស។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

ប៉ូលិស
ទូរសព្ទទៅលេខ 000 ក្នុងគ្រាអាសន្នបន្ទាន់ ឬលេខ 131 444 សម្រាប់វត្តមានរបស់ប៉ូលិស (មិនមែនជាករណីអាសន្នបន្ទាន់)។

# អំពើហិង្សាក្នុងគ្រួសារ



- នៅប្រទេសអូស្ត្រាលី មានច្បាប់នានាដើម្បីការពារមនុស្សពីអំពើហិង្សាក្នុងគ្រួសារ។
- អំពើហិង្សាក្នុងគ្រួសារអាចមានទម្រង់ជាច្រើន រួមទាំងការរំលោភបំពានផ្លូវកាយ ផ្លូវភេទ ផ្លូវចិត្ត ពាក្យសម្តី អារម្មណ៍ និងសេដ្ឋកិច្ច។
- គ្មាននរណាម្នាក់គួរតែរស់នៅក្នុងភាពភ័យខ្លាច ដោយអំពើហិង្សាក្នុងគ្រួសារនោះ ទេ។ ប៉ូលិស និងតុលាការចាត់ទុកថាវាជាឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរមួយ។
- ប៉ូលិស និងតុលាការអាចចេញដីកាប្រាប់សមាជិកគ្រួសារ ឱ្យបញ្ឈប់អំពើហិង្សាក្នុងគ្រួសារនា ពេលអនាគត។ នេះត្រូវបានគេហៅថា 'ដីកាអន្តរាគមន៍'។
- ប្រសិនបើសមាជិកគ្រួសារមិនបញ្ឈប់អំពើហិង្សានោះទេ ពួកគេនឹងមានបញ្ហា ជាមួយនឹង ច្បាប់។
- មានសេវាកម្មឥតគិតថ្លៃពិសេស ដែលអាចជួយមនុស្សដែលមានអារម្មណ៍ថាមិនមាន សុវត្ថិភាពនៅផ្ទះ។ សេវាកម្មទាំងនេះរួមមានសេវាកម្មផ្តល់ទីជំរករបស់ស្ត្រី សេវាកម្មប្រឹក្សាយោបល់ និងដំបូន្មានផ្លូវច្បាប់។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

សេវាកម្មច្បាប់សម្រាប់ស្ត្រី
1800 655 037

បណ្តាញទូរសព្ទជំនួយប្រចកទ្វារអំពើហិង្សាក្នុងគ្រួសារ
1800 800 098

ប៉ូលិស
ទូរស័ព្ទទៅលេខ 000 ក្នុងគ្រាអាសន្នបន្ទាន់ ឬលេខ 131 444 សម្រាប់វត្តមានរបស់ ប៉ូលិស (មិនមែនជាករណីអាសន្នបន្ទាន់)។

# ការជួលទីលំនៅ




- ម្ចាស់ផ្ទះត្រូវតែរក្សាទ្រព្យសម្បត្តិក្នុងស្ថានភាពសមរម្យ។
- អ្នកជួលត្រូវតែប្រាប់ម្ចាស់ផ្ទះ ប្រសិនបើទ្រព្យសម្បត្តិណាមួយត្រូវបានខូចខាត។
- ម្ចាស់ផ្ទះបង់ថ្លៃជួសជុល បើសិនការខូចខាតមិនបង្កឡើងដោយអ្នកជួលទីលំនៅទេ។
- អ្នកជួលទីលំនៅត្រូវបង់ថ្លៃជួល និងរក្សាទ្រព្យសម្បត្តិឱ្យស្អាត មានសណ្តាប់ធ្នាប់ និងមានរបៀបរៀបរយល្អ។
- ស្នើសុំបង្កាន់ដៃដើម្បីបញ្ជាក់ថាអ្នកបានបង់ថ្លៃជួល។
- អ្នកជួលទីលំនៅមិនត្រូវបញ្ចេញសំឡេងខ្លាំងពេក ឬរំខានអ្នកជិតខាងឡើយ។
- អ្នកមិនអាចត្រូវបានគេបណ្តេញចេញ ដោយគ្មានដីកាពីតុលាការ ឬសាលាក្តីឡើយ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

RentRightSA (ទីភ្នាក់ងារ សិទ្ធិជួលទីលំនៅ រដ្ឋអូស្ត្រាលីខាងត្បូង)
1800 060 462

# អាពាហ៍ពិពាហ៍



- នៅប្រទេសអូស្ត្រាលី អាពាហ៍ពិពាហ៍គឺធ្វើឡើងរវាងមនុស្សពីរនាក់ដែលមានអាយុ 18 ឆ្នាំ ឬ អាយុលើសនេះ។
- ក្នុងកាលៈទេសៈពិសេស មនុស្សវ័យក្មេងដែលមានអាយុ 16 ឬ 17 ឆ្នាំ អាចរៀបការបាន ប្រសិនបើតុលាការផ្តល់ការអនុញ្ញាត។ វាជាករណីកម្រណាស់ដែលតុលាការ ផ្តល់ការអនុញ្ញាតដូចនេះ។
- ច្បាប់មិនអនុញ្ញាតឱ្យនរណាម្នាក់ដែលមានអាយុក្រោម 18 ឆ្នាំ ត្រូវបាននាំចេញ ទៅបរទេសដើម្បីរៀបការឡើយ។
- នៅប្រទេសអូស្ត្រាលី មិនមានច្បាប់ណាដែលតម្រូវឱ្យមនុស្សរៀបការស្របច្បាប់ ដើម្បីរស់នៅជាមួយគ្នានោះទេ។
- ការរៀបការមិនផ្តល់សិទ្ធិឱ្យប្តី ឬប្រពន្ធក្នុងការរួមភេទជាមួយមនុស្សដែលខ្លួនរៀប ការជាមួយនោះទេ។ ប្រសិនបើមនុស្សម្នាក់មិនយល់ព្រមចំពោះការរួមភេទទេ នេះហៅថាការរំលោភ សូម្បីតែរវាងមនុស្សពីរនាក់ដែលបានរៀបការក៏ដោយ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

# ការបែកគ្នា និង ការលែងលះគ្នា



- នរណាម្នាក់ដែលមិនចង់រក្សាស្ថានភាពដែលបានរៀបការហើយ អាចលែងលះគ្នាបាន។ វាមិនសំខាន់ទេដែលថានរណាជាអ្នកខុសនោះ។

- ការលែងលះគ្នាគឺជាការបញ្ចប់អាពាហ៍ពិពាហ៍ជាផ្លូវការ និងស្របច្បាប់។ អ្នកត្រូវតែដាក់ពាក្យសុំទៅតុលាការដើម្បីលែងលះគ្នា។

- មុនពេលអ្នកអាចស្នើសុំការលែងលះគ្នា អ្នកត្រូវតែឈប់រស់នៅជាប្តីប្រពន្ធយ៉ាងហោច ណាស់ 12 ខែ។

- វាអាចធ្វើទៅបានដើម្បីបែកគ្នា ខណៈពេលកំពុងរស់នៅក្នុងផ្ទះតែមួយ  ដរាបណា អ្នកលែងចែករំលែកសកម្មភាពធម្មតានៃអាពាហ៍ពិពាហ៍ ដូចជាការដេកជាមួយគ្នា ការពិសាអាហារជាមួយគ្នា ការចែករំលែកគណនីធនាគារ ឬការចេញទៅក្រៅជាមួយ គ្នាជាមួយកូនៗរបស់អ្នក។

- មានច្បាប់គ្រួសារស្តីអំពីការថែទាំកុមារ និងការបែងចែកទ្រព្យសម្បត្តិបន្ទាប់ពីការបែក គ្នា។ ច្បាប់ទាំងនេះអាចអនុវត្ត មិនថាអ្នករៀបការស្របច្បាប់ឬអត់នោះទេ។

- ប្រសិនបើអ្នកកំពុងពិចារណាពីការបែកគ្នា ឬបានបែកគ្នាហើយ អ្នកគួរតែស្វែងរក ដំបូន្មានផ្លូវច្បាប់។ មេធាវីអាចជួយអ្នកឱ្យស្វែងយល់ពីសិទ្ធិ និងទំនួលខុសត្រូវស្រប ច្បាប់របស់អ្នក ហើយពន្យល់ពីរបៀបដែលច្បាប់អនុវត្តចំពោះអ្នក។

- ការបែកគ្នា ឬការលែងលះអាចប៉ះពាល់ដល់ស្ថានភាពអន្តោប្រវេសន៍របស់អ្នក។ អ្នកគួរតែទទួលបានដំបូន្មានផ្នែកច្បាប់អំពីបញ្ហានេះ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

តុលាការច្បាប់គ្រួសារ
1300 352 000

# កុមារ និងការបែកគ្នា




- ឪពុកម្តាយទទួលខុសត្រូវចំពោះកូនរបស់ពួកគេ។ នេះមិនផ្លាស់ប្តូរទេ ទោះបីជាឪពុកម្តាយបែកគ្នាក៏ដោយ។
- កុមារមានសិទ្ធិទៅជួបឪពុកម្តាយរបស់ពួកគេ ដរាបណាពួកគេមានសុវត្ថិភាព។
- ឪពុកម្តាយដែលបែកគ្នាភាគច្រើន ស្វែងរកវិធីដើម្បីបន្តចែករំលែកការថែទាំកូនរបស់ពួកគេ។
- ឪពុកម្តាយដែលបែកគ្នាខ្លះ មិនអាចយល់ស្របអំពីការរៀបចំសម្រាប់កូនរបស់ពួក គេទេ។ មេធាវីគ្រួសារអាចផ្តល់ដំបូន្មានផ្លូវច្បាប់ និងជួយឪពុកម្តាយឱ្យឈានដល់ កិច្ចព្រមព្រៀងមួយ។
- ក្នុងករណីធ្ងន់ធ្ងរ តុលាការគ្រួសារអាចសម្រេចពីអ្វីដែលគួរកើតឡើងជាមួយកុមារ។
- ការសម្រុះសម្រួលគ្រួសារ គឺជាកន្លែងដែលឪពុកម្តាយជួបគ្នា ដោយមានជំនួយពីអ្នកសម្រុះសម្រួលឯករាជ្យម្នាក់ ដើម្បីពិភាក្សាអំពីការរៀបចំសម្រាប់កុមារដោយ មិនចាំបាច់ទៅតុលាការ។
- ឪពុកម្តាយម្នាក់អាចត្រូវបានស្នើសុំឱ្យបង់ 'ប្រាក់ចិញ្ចឹមកូន' ដល់ឪពុកម្តាយម្នាក់ ទៀតដើម្បីជួយពួកគេមើលថែទាំកូន។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450



# ការថែទាំកុមារ

- ឪពុកម្ដាយត្រូវតែថែទាំកូន និងការពារពួកគេពីគ្រោះថ្នាក់។
- ឪពុកម្ដាយមានសិទ្ធិបង្រៀនកូនពីរបៀបធ្វើឥរិយាបទ។ ឪពុកម្ដាយមិនត្រូវធ្វើបាប កូនតាមរយៈការដាក់វិន័យទេ។
- ក្រសួងការពារកុមារអាចចាត់វិធានការ ដើម្បីការពារកុមារពីឪពុកម្ដាយដែលមិនយក ចិត្តទុកដាក់ចំពោះកូន ឬធ្វើឱ្យពួកគេឈឺចាប់។
- មានសេវាកម្មឥតគិតថ្លៃនានា ដែលអាចជួយឪពុកម្ដាយក្នុងការប្រឹក្សាយោបល់ ការថែទាំកុមារ និងការប្រឹក្សាយោបល់គ្រួសារ។
- អ្នកវិជ្ជាជីវៈដែលធ្វើការជាមួយកុមារត្រូវតែធ្វើរបាយការណ៍ទៅក្រសួងការពារកុមារ ប្រសិនបើពួកគេគិតថាកុមារអាចតទទួលរងការឈឺចាប់។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

បណ្ដាញទូរស័ព្ទជំនួយឪពុកម្ដាយ
1300 364 100

ក្រសួងការពារកុមារ
បណ្ដាញទូរសព្ទរបាយការណ៍ការរំលោភបំពានលើកុមារ 131 478
ការថែទាំក្នុងគ្រាមានវិបត្តិ (ក្រោយម៉ោងធ្វើការ) 131 611

ប៉ូលិស
ទូរស័ព្ទទៅលេខ 000 ក្នុងគ្រាអាសន្នបន្ទាន់ ឬលេខ 131 444 សម្រាប់វត្តមានរបស់ប៉ូលីស (មិនមែនជាករណីអាសន្នបន្ទាន់)។

# ការសម្រេចចិត្តរបស់រដ្ឋាភិបាល



- ការសម្រេចចិត្តនានារបស់មន្ត្រីរដ្ឋាភិបាល ត្រូវតែបានធ្វើឡើងដោយស្របទៅតាមបទប្បញ្ញត្តិ។

- អ្នកមានសិទ្ធិទទួលបានដំបូន្មានផ្លូវច្បាប់ និងសួរសំណួរនានាអំពីការសម្រេចចិត្ត របស់រដ្ឋាភិបាលដែលប៉ះពាល់ដល់អ្នក។

- ពេលខ្លះ អ្នកអាចស្នើសុំឱ្យមានការកែប្រែការសម្រេចចិត្តទាំងនេះ។

- អ្នកក៏អាចធ្វើបណ្ដឹងតវ៉ាទៅអាជ្ញាធរស៊ើបអង្កេតបណ្ដឹងតវ៉ាពលរដ្ឋ រដ្ឋអូស្ត្រាលី ខាងត្បូង (Ombudsman SA) ឬអាជ្ញាធរស៊ើបអង្កេតបណ្ដឹងតវ៉ាពលរដ្ឋសហព័ន្ធ (Commonwealth Ombudsman) ផងដែរ ប្រសិនបើអ្នកជឿថាការសម្រេចចិត្តរបស់រដ្ឋាភិបាលខុស។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

អាជ្ញាធរស៊ើបអង្កេតបណ្ដឹងតវ៉ាពលរដ្ឋ សហព័ន្ធ
(Commonwealth Ombudsman)
1300 362 072

អាជ្ញាធរស៊ើបអង្កេតបណ្ដឹងតវ៉ាពលរដ្ឋ រដ្ឋអូស្ត្រាលីខាងត្បូង (Ombudsman SA)
8226 8699
1800 182 150 (អ្នកហៅទូរស័ព្ទពីទីជនបទ)

# ការងារ




- មានច្បាប់ជាច្រើនដែលការពារសិទ្ធិរបស់អ្នកនៅកន្លែងធ្វើការ រួមមាន៖
  - ចំនួនប្រាក់បៀវត្សរ៍ដែលអ្នកទទួលបាន
  - សំណង ប្រសិនបើអ្នករងរបួសនៅកន្លែងធ្វើការ
  - ការប្រព្រឹត្តដោយយុត្តិធម៌នៅកន្លែងធ្វើការ
  - មានសុវត្ថិភាពនៅកន្លែងធ្វើការ
  - កំណត់ត្រាអំពីបៀវត្សរ៍ ពន្ធ និងប្រាក់សោធននិវត្តន៍របស់អ្នក។
- ប្រសិនបើអ្នកជាសមាជិកសហជីព ពួកគេអាចផ្តល់ដំបូន្មានដល់អ្នក និងជួយការពារ សិទ្ធិរបស់អ្នកនៅកន្លែងធ្វើការ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

ភ្នាក់ងារស៊ើបអង្កេតបណ្តឹងតវ៉ាពលរដ្ឋ ការងារមានយុត្តិធម៌ (បៀវត្សរ៍ និងសិទ្ធិការងារ)
(Fair Work Ombudsman)
131 394

មជ្ឈមណ្ឌលរបស់ស្ត្រីធ្វើការ រដ្ឋអូស្ត្រាលីខាងត្បូង
(Working Women's Centre SA)
1800 652 697

# ការផាកពិន័យ



- ការផាកពិន័យគឺជាប្រភេទនៃការដាក់ទណ្ឌកម្ម ដែលអ្នកត្រូវតែបង់ប្រាក់ចំពោះការបំពានច្បាប់។

- ប្រសិនបើអ្នកមិនអាចមានលទ្ធភាពបង់ការផាកពិន័យរបស់អ្នក ឱ្យបានពេញលេញតាមកាលបរិច្ឆេទកំណត់ទេ សូមពិភាក្សាជាមួយអង្គភាពអនុវត្តការផាកពិន័យ និងការប្រមូលប្រាក់បំណុលវិញ។

- អង្គភាពអនុវត្តការផាកពិន័យ និងការប្រមូលប្រាក់បំណុលវិញ អាចរៀបចំការទូទាត់ប្រាក់ដោយផ្អែកលើលទ្ធភាពក្នុងការទូទាត់ប្រាក់របស់អ្នក។

- ប្រសិនបើអ្នកមិនធ្វើកិច្ចព្រមព្រៀងជាមួយអង្គភាពអនុវត្តការផាកពិន័យ និងការប្រមូលប្រាក់បំណុលវិញទេ ពួកគេមានអំណាចក្នុងការបង្ខំអ្នកឱ្យបង់ប្រាក់ពិន័យ របស់អ្នក។

- សូមកុំព្រងើយកន្តើយនឹងការផាកពិន័យរបស់អ្នក – ប្រសិនបើអ្នកមិនអាចបង់បាន ទេ សូមសុំជំនួយ។

សម្រាប់ព័ត៌មានបន្ថែម

គណៈកម្មការសេវាកម្មច្បាប់ (ការណែនាំទូទៅ និងការបញ្ជូនបន្ត)
1300 366 424
www.lsc.sa.gov.au

សេវាកម្មបកប្រែភាសាសរសេរ និងបកប្រែផ្ទាល់មាត់ (TIS)
131 450

អង្គភាពអនុវត្តប្រាក់ពិន័យ និងការ ប្រមូលប្រាក់បំណុលវិញ
1800 659 538

# កំណត់ចំណាំ

Legal Services
Commission South Australia

បោះពុម្ពផ្សាយដោយមានការគាំទ្រពី មូលនិធិច្បាប់នៃរដ្ឋអូស្ត្រាលីខាងត្បូង

The LAW FOUNDATION of SA Incorporated

ខ្លឹមសារ និងរូបភាពមួយចំនួនសម្រាប់ធនធាននេះត្រូវបានកែសម្រួលពី តើច្បាប់ជាអ្វី? ច្បាប់អូស្ត្រាលីនៅក្នុងប្រទេសថ្មីរបស់ខ្ញុំ ផលិតដោយ គណៈកម្មការជំនួយផ្លូវច្បាប់អូស្ត្រាលី។

ការបដិសេធមិនទទួលខុសត្រូវ៖ ច្បាប់ផ្លាស់ប្តូរជាញឹកញាប់ ហើយព័ត៌មាននៅក្នុងការបោះពុម្ពផ្សាយនេះ ប្រហែលជាមិនទាន់សម័យកាលទេ។ ព័ត៌មានក្នុងការបោះពុម្ពផ្សាយនេះ គឺជាការណែនាំទូទៅប៉ុណ្ណោះ។ វាមិនមែនជាដំបូន្មានផ្លូវច្បាប់ទេ។ យើងសូមលើកទឹកចិត្តប្រជាជនឱ្យស្វែងរកដំបូន្មានបុគ្គលផ្ទាល់អំពីបញ្ហាផ្លូវច្បាប់របស់ពួកគេ។

© គណៈកម្មការសេវាកម្មច្បាប់ ខែមីនា ឆ្នាំ 2015 បានធ្វើបច្ចុប្បន្នភាព នៅខែកុម្ភៈ ឆ្នាំ 2022។